

ការយកឈ្នះតាមរយៈការសរសើរដំកើង



(17)

នេះគឺជាពាក្យរបស់លោក ដេវក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> ទ្រង់បានតាំងឲ្យមានសេចក្តីសរសើរដោយសារមាត់កូនក្មេង និងកូនដែលនៅបៅដោះ ដោយព្រោះពួកឥតតាំងនឹងទ្រង់ ដើម្បីនឹងធ្វើឲ្យពួកខ្មាំងសត្រូវ
> ព្រមទាំងពួកសងសឹកបានស្ងៀមនៅ។ [ទំនុកដំកើង ៨:២]

រឿងមួយដែលយើងកត់សម្គាល់នៅក្នុងទំនុកដំកើងរបស់ដាវីឌ
គឺថាគាត់និយាយពីការដោះស្រាយមួយយ៉ាងអស្ចារ្យជាមួយនឹងសត្រូវរបស់គាត់។ ប្រសិនបើនិយាយពីមនុស្សម្នាក់ដែលមានសត្រូវ
គាត់គឺជា ដាវីឌ។

ប៉ុន្តែគាត់បានដឹងអំពីការសម្ងាត់ក្នុងការដោះស្រាយជាមួយនឹងសត្រូវរបស់គាត់។
គាត់បានដឹងពីភាពអាថកំបាំងនៃការការពារនៃព្រះវត្តមានរបស់ព្រះជាម្ចាស់ និងជំនួយមកពីព្រះ
ហើយនៅទីនេះគាត់បានបង្ហាញពីអាថកំបាំងនេះយ៉ាងសាមញ្ញ។
វាគឺជាការថ្វាយសិរីរុងរឿងដល់ព្រះ។ លោកពោលថា៖
«ទ្រង់បានតាំងឲ្យមានសេចក្តីសរសើរដោយសារមាត់កូនក្មេង
និងកូនដែលនៅបៅដោះ»។

តាមធម្មជាតិកូនក្មេង
និងកូនដែលនៅបៅដោះគឺជាមនុស្សទន់ខ្សោយបំផុត
ប៉ុន្តែនៅពេលដែលមានសេចក្តីសរសើរចេញពីមាត់មនុស្សដែលទន់ខ្សោយបំផុត ប្រសិទ្ធភាពរបស់វាគឺដើម្បីធ្វើឲ្យពួកខ្មាំងសត្រូវ
ព្រមទាំងពួកសងសឹកបានស្ងៀមនៅ។

ព្រះគម្ពីរបង្ហាញយើងយ៉ាងច្បាស់ថា យើងគ្រប់គ្នាមានសត្រូវម្នាក់ជាអ្នកសងសឹក-ជាម្នាក់រង់ចាំតែបំផ្លាញយើង។ វានោះឈ្មោះថា
សាតាំង។ វាគឺជាអារក្ស។ វាគឺជាអ្នកចោទប្រកាន់ពួកបរិសុទ្ធ។

វាគឺជាម្នាក់ដែលបានបកស្រាយខុសចំពោះយើង
ដែលតែងតែប្រឆាំងនឹងយើង
ដែលបានបកស្រាយខុសនូវអ្វីដែលយើងធ្វើ
ដែលចោទប្រកាន់យើងនៅចំពោះមុខបល្ល័ង្ករបស់ព្រះ។

តើយើងអាចបញ្ឈប់វាបានដោយរបៀបណា?
តើយើងអាចធ្វើឱ្យវាស្ងៀមស្ងាត់យ៉ាងដូចម្តេចបាន?
ចម្លើយគឺដោយការសរសើរ។
នៅពេលការសរសើរដំកើងឡើងទៅព្រះ
ការសរសើរបំបិទមាត់សាតាំង។

ការសរសើរធ្វើឲ្យការចោទប្រកាន់របស់វាត្រូវស្ងាត់។
ការសរសើរបិទមាត់របស់វា
ហើយយើងមានសេរីភាពដោយមិនមានការរារាំងចូលក្នុងព្រះវត្តមានរ
បស់ព្រះជាម្ចាស់។ យើងរស់នៅចេញពីជីវិតរបស់យើង
ដោយគ្មានការផ្តោលទោសបន្តជាប់ជានិច្ចពីការចោទប្រកាន់របស់សា
តាំងទៀតឡើយ។ សូមចាំថា
ការសរសើរគឺជារបៀបដើម្បីនាំយកព្រះជាម្ចាស់មកនៅខាងអ្នកប្រឆាំ
ងនឹងអារក្ស។

: WD-WFTW-017-KHM
: 24 Feb 2026
: derekprince.com/km/resources

